# ៣

# បុណ្យ និង បាប

**បុណ្យ** គឺអំពើល្អ អំពើកុសល **បាប** គឺអំពើអាក្រក់ អំពើអកុសល ។

ក្នុងធម៌ គេប្រើ ពាក្យ **កម្ម** ជំនួសពាក្យ អំពើ ដូចជាពាក្យថា កម្មចាស់ គឺកម្មពីអតីតកាល ឬ ពីជាតិមុន កម្មថ្មី គឺកម្ម បច្ចុប្បន្ន។ ដូច្នេះ អត់មានកម្មអនាគតទេ ពីព្រោះមិនទាន់បានធ្វើផង ម្តេចនឹងមានកម្មទៅកើត ។

ចំពោះមនុស្សយើងម្នាក់ៗ យើងអាចធ្វើកម្ម ដោយកាយ ហៅថា **កាយកម្ម** ដោយវាចា ហៅថា **វចីកម្ម** និងដោយចិត្ត ហៅថា **មនោកម្ម** ។

កម្មដែលអ្នកដទៃមើលមិនឃើញ ហើយមានតែអ្នកដែលធ្វើកម្មនោះទេដែលដឹង គឺកម្មដោយចិត្ត ។ តើកម្មដោយចិត្ត ធ្វើ ដោយរបៀបណា? លក្ខណរបស់ចិត្ត គឺដឹង អារម្មណ៍ ហើយអារម្មណ៍មាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ (ការប៉ះខ្ទប់កាយទៅនឹងវត្ថុផ្សេងៗ) និង ធម្មារម្មណ៍ (គឺអារម្មណ៍ចាស់ដែលចិត្តធ្លាប់សោយ ហើយនឹកទៅរកអារម្មណ៍នោះម្តងទៀត)។ កាលណាភ្នែកឃើញរូប ចិត្តកើតឡើង អាចពេញចិត្ត ឬ មិនពេញចិត្តនឹងរូបនោះ ពោលគឺកើត សេចក្តីស្រឡាញ់ ឬ ស្អប់ ឬ មិនស្រឡាញ់មិនស្អប់ ។ បើស្រឡាញ់ អាចកើតតណ្ហា មានការចង់បាន រហូតដល់មាន លោភៈ បើស្អប់ អាចកើតចិត្តមួម៉ៅ ចិត្តទោសៈ ជាដើម ។ យើងអាចមិនធ្វើបាប ដោយកាយ ដោយវាចាបាន តែដោយចិត្តពិបាកនឹងថាណាស់ ពីព្រោះ កាលណាយើងនឹកគិតទៅអ្វីមួយជា <u>អកុសល</u> នឹកខឹងនឹងអ្នកណាមួយ ដែលធ្វើឲ្យយើងខូចប្រយោជន៍ នៅពេលនោះចិត្តក៏ខឹងឡើង ហើយគិតរកមធ្យោបាយ នឹងសងសឹកអ្នកនោះ ។ ការគិតសងសឹកនេះ គឺមនោកម្ម ជាអំពើអកុសល ដូច្នេះជាបាប ។ ដោយ បុណ្យនិងបាប ច្រើន

តែយល់មិនដូចគ្នា យើងថាល្អ គេថាអាក្រក់ យើងថាអាក្រក់ គេថាល្អ តើត្រូវយកអ្វីជាគ្រឿងកំណត់ ជាគ្រឿងសំរាប់វាស់ ឲ្យដឹងថា ណាល្អ ណាអាក្រក់? ឆ្លើយថា យកលទ្ធផលរបស់វា ជាគ្រឿងកំណត់ ជាគ្រឿងសំរាប់វាស់។

យកលទ្ធផលបានន័យថា

- អំពើណាឲ្យ សេចក្តីសុខដល់ខ្លួនឯងផង និងដល់ អ្នកដទៃផង អំពើនោះ ជា បុណ្យ។
- អំពើណាឲ្យសុខដល់អ្នកដទៃ តែឲ្យទុក្ខដល់ខ្លួនឯងនៅពេលដំបូង បន្ទាប់មកក៏ឲ្យសុខវហូត អំពើនោះក៏ជាបុណ្យដែរ។
- អំពើណាឲ្យ ទុក្ខដល់ខ្លួនឯង ឬ ឲ្យទុក្ខដល់ អ្នកដទៃ អំពើនោះជា បាប។
- អំពើណាឲ្យ ទុក្ខដល់ខ្លួនឯងផង និងដល់អ្នកដទៃផង អំពើនោះរឹតតែជា បាប។
- អំពើណាឲ្យ សុខដល់ខ្លួនឯង តែឲ្យទុក្ខដល់អ្នកដទៃ អំពើនោះជា បាប។
- អំពើណា មិនទាន់ឲ្យទុក្ខ ក្នុងបច្ចុប្បន្ននេះទេ តែនឹងឲ្យទុក្ខនៅពេលខាងមុខ ឬ នៅជាតិខាងមុខតៗទៅ អំពើនោះក៏ជា បាប ដែរ។

តាមការយល់ឃើញរបស់ខ្ញុំ យកលទ្ធផលរបស់កម្មជាខ្នាត ជាការជាក់ស្តែងជាងគេ។ ពីព្រោះបាបនិងបុណ្យ យើងមើលមិនឃើញទេ គេថាចុះនរក យមបាលបោះចូលក្នុងខ្ទះស្ពោតស្ពោរទាំងរស់ យើងគ្រាន់តែឮ តែមិនដែលឃើញទេ តែចំពោះអ្នកធ្វើអំពើអាក្រក់ ធ្វើឲ្យអ្នកដទៃរងទុក្ខវេទនា ព្រោះតែអំពើអាក្រក់នោះ យើងធ្លាប់ឃើញ មិនត្រឹមតែបាបទេ អ្នកនោះអាចត្រូវទណ្ឌកម្មដោយច្បាប់រដ្ឋប្បវេណីទៀតផង។ ចំពោះអំពើអាក្រក់បែបនេះ បើមានអ្នកណាមួយគេថាអត់បាបទេ អ្នកឯងគ្រាន់តែសារភាពកំហុសនោះទៅ រួចខ្លួនទៅហើយ តើយើងជឿថាអត់បាបរួចខ្លួនដែរទេ? មុននឹងឆ្លើយថាយ៉ាងណា គប្បីយកបញ្ញាមកប្រើ តើអំពើនោះ ជាបាប ឬជាបុណ្យ?

បើអំពើណាមួយយើងយល់ថាជាបាប ហើយគេថាជាបុណ្យ តើអំពើនោះឲ្យលទ្ធផល

ជាបុណ្យតាមមាត់អ្នកនោះឬទេ ? ការពិតនៅតែការពិតដដែល ហើយអ្នកទទួលផល គឺអ្នកដែលធ្វើ មិនមែនអ្នកអះអាងជានានោះទេ។ ដូច្នេះ **ខ្លួនទីពឹងខ្លួន** (នេះតាមពុទ្ធដីកា ) យើងជឿតែអ្វីដែលគួរជឿ ដែលសមហេតុសមផល។

ឧទាហរណ៍មួយ ដែលថា ការយល់ បុណ្យនិងបាប មិនដូចគ្នា

លោក « ក » រើសបាន កញ្ចប់ប្រាក់មួយព្រមទាំងសំបុត្រអត្តសញ្ញាណ នៅតាមផ្លូវ ។ ដោយគាត់ខ្លាចបាប គាត់មិនហ៊ានទុកកញ្ចប់ប្រាក់នោះទេ ? ហើយគាត់សួរថាតើឲ្យគាត់ធ្វើដូចម្តេច ?

- អ្នកមួយឆ្លើយថា ឲ្យយកទៅប្រគេនព្រះសង្ឃ ។
- ម្នាក់ទៀតឆ្លើយថា ឲ្យយកទៅប្រគល់ឲ្យប៉ូលីសនៅស្នងការដ្ឋាន ។

តាមខ្ញុំយល់ ហេតុដែលនាំឲ្យ បុណ្យ និង បាប យល់មិនដូចគ្នា មកពីយើងមិនហ៊ានទទួលការពិត ។ ការពិតយ៉ាងណា ? ការពិតគឺ « ***ទាំងយើងទាំងគេ សុទ្ធតែចង់បានសេចក្តីសុខទាំងអស់គ្នា*** » មិនដែលនរណា ចង់បានទុក្ខទេ (នេះជាច្បាប់ធម្មជាតិមួយដែរ) ហើយដែលហៅថា បាប គឺអំពើណា ដែលនាំមកនូវទុក្ខ ដល់ខ្លួនយើង ឬ នាំមកនូវទុក្ខដល់អ្នកដទៃ ។ ឧបមា ធម៌ព្រះ ក្នុងសីល ៥ ថា « ផឹកស្រាបាប » ។ ហេតុអ្វីក៏បាប ពីព្រោះកាលណាយើងផឹកស្រា យើងធ្វើបាបខ្លួនយើង ។ យើងធ្វើបាបខ្លួនយើង ដោយរបៀបណា ? ពីព្រោះស្រា ដល់ផឹកច្រើនទៅវាអាចធ្វើឲ្យយើង រលាកក្រពះ ឬធ្វើទុក្ខថ្លើម ជាដើម ។ ដូច្នេះ តើអ្នកណា ជាអ្នកឈឺ ? គឺខ្លួនយើងនេះឯងដែលឈឺ មិនមែនមិត្តសំឡាញ់ មកឈឺជំនួសយើងទេ ។ ហេតុនេះហើយបានជាថា « ផឹកស្រាបាប » ។ ហើយ បាបនេះទៀត មិនមែនព្រះពុទ្ធ ឬ ព្រះអាទិទេពណា ឲ្យមកយើង ដោយដាក់ទណ្ឌកម្មនោះទេ ។ គឺ កម្ម (អំពើ) របស់យើង ដែលវាឲ្យ បាប មកយើង ។ ដូច្នេះ បុណ្យ ឬ បាប

មិនមែន ជារង្វាន់ ឬជា ទណ្ឌកម្ម ដែលព្រះពុទ្ធ ឲ្យមកយើងនោះទេ ។ ព្រះពុទ្ធគ្រាន់តែប្រាប់យើងថា បើយើងធ្វើបែបនេះ យើងនឹងបានបុណ្យ បើយើងធ្វើបែបនោះ យើងនឹងបានបាប ។ តែកុំភ្លេចថាយើងជាអ្នកធ្វើ មិនមែនព្រះពុទ្ធធ្វើជំនួសយើងទេ ។ មានអ្នកខ្លះនិយាយថា « ខ្ញុំឃើញ គេធ្វើបាប ធ្វើអំពើអាក្រក់ទៅលើអ្នកដទៃ យ៉ាងច្រើន ហើយគេនៅតែសុខសប្បាយ មានទ្រព្យសម្បត្តិកាន់តែច្រើនទៅៗ » ។ នេះជាការពិត ហើយ ខ្ញុំក៏ធ្លាប់បានឃើញដែរ ។ តែខ្ញុំសូមសួរថា៖ បើសិនជាយើងកំពុងតែរស់នៅ បានសុខសប្បាយស្រាប់តែមានអ្នកដទៃមកធ្វើឲ្យយើងកើតទុក្ខ ហើយបើមានទ្រឹស្តីណាមួយថា អំពើអ្នកដទៃនោះជា បុណ្យ តើយើងយល់ព្រមទេ ?

ខ្ញុំសូមឆ្លើយជំនួសថាយើងមិនសុខចិត្តទេ ។ ចុះហេតុអ្វី ក៏នៅមានអ្នកធ្វើបាបគេ ហើយនៅតែបានសុខសប្បាយ ? មកដល់សំណួរនេះ ខ្ញុំទាល់ហើយ ពីព្រោះទាក់ទងនឹងការជឿ ឬ មិនជឿរបស់យើងម្នាក់ៗ ឬក៏ថា គួរជឿ ឬមិនគួរជឿ របស់យើងម្នាក់ៗ ។ តាមទ្រឹស្តីព្រះពុទ្ធសាសនា កាលណាយើងនៅជា បុថុជ្ជន នៅឡើយ « យើងស្លាប់ទៅកើតទៀត » ។ ដោយយើងសព្វថ្ងៃនេះ ធ្វើបុណ្យផង ហើយក៏ធ្លាប់ធ្វើបាបដែរ ដូច្នេះគ្រប់តែជាតិដែលយើងកើត យើងតែងតែធ្វើ បុណ្យនិងបាប មិនខុសពីជាតិនេះប៉ុន្មានទេ ហើយបុណ្យនិងបាបដែលសន្សំពីអតីតជាតិទាំងអស់នេះហើយ ជាពិសេស គឺបុណ្យពីអតីតជាតិ ដែលធ្វើឲ្យមនុស្សធ្វើបាបគេ នៅតែបានសុខសប្បាយដដែល ។ តែបើជឿទៅលើកម្មផលនេះត្រូវឲ្យឆាប់ឈប់ធ្វើអំពើអាក្រក់ទៀតទៅ ពីព្រោះបើប្រាក់ដែលសន្សំអាចចាយវាយអស់ យ៉ាងណាបុណ្យដែលបានសន្សំទុកពីមុនមក ក៏អាចនឹងអស់យ៉ាងនោះដែរ។ ហើយតែអស់បុណ្យហើយ ទុក្ខក៏វាមកដល់ជាមួយគ្នាដែរ ។ ជាទូទៅ ការប្រើបញ្ញាជាការសំខាន់ណាស់ មានអ្នកខ្លះឈប់កាន់សាសនាព្រះពុទ្ធ ហើយទៅកាន់សាសនាដទៃ ដោយនិយាយថា សាសនាយើងព្រះមិនជួយដូចសាសនាគេដទៃទេ។ ពីព្រោះ

សាសនាគេ ព្រះគេជួយ គឺព្រះគេអាច ពិន័យ ឬ ឲ្យរង្វាន់ដល់អ្នកដែលកាន់សាសនារបស់គេនោះៗ តែជំនឿបែបនេះតាមខ្ញុំបានស្តាប់តាមទូរទស្សន៍ថា ពួកក្មេងៗជំនាន់ក្រោយនៃប្រទេសដែលកាន់សាសនានោះ ចាប់ឈប់ជឿហើយៗ ចំពោះខ្ញុំឥតមានអ្វីប្លែកទេ អ្នកណាធ្វើ គឺអ្នកនោះឯងជាអ្នកទទួលផល បើយើងខំរៀន គឺយើងជាអ្នកទទួលចំណេះ មិនដែលអត់ទាំងបានរៀនផង ហើយស្រាប់តែចេះដូចគេដែរ គ្រាន់តែទៅបន់ព្រះ នោះពុំសមទេ ។ ចុះហេតុអ្វី បានជាក្នុងកម្មវិធីបុណ្យ ច្រើនតែមានការទទួល សីល៥ ពីព្រះសង្ឃ ? ចម្លើយគឺ មុននឹងធ្វើបុណ្យ យើងត្រូវជម្រះចិត្តយើងឲ្យបានស្អាតបរិសុទ្ធ ជាមុនសិន ដើម្បីនឹងបានទទួល កុសលច្រើនពីបុណ្យដែលយើងនឹងធ្វើនោះ ។